# ព្រះរាជក្រម

នស/រកម/១២០៤/០០១

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិថ្វាយដល់អតីតព្រះមហាក្សត្រ និងព្រះរាជមហេសី នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការរៀបចំព្រះបរមរាជវាំង និង ព្រះរាជបុព្វសិទ្ធិ ថ្វាយអតីតព្រះមហាក្សត្រ និង ព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំព្រះបរមងារ និង ព្រះរាជបុព្វសិទ្ធិថ្វាយអតីត **ព្រះមហាក្សត្រ និង ព្រះមហេសី** នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសំដែងនូវកតញ្ញូតា កតវេទិតាចំពោះព្រះមហាគុណូបការៈដ៏ថ្លៃថ្លាខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់បានបំរើប្រជារាស្ត្រ ប្រជាជាតិ និង មាតុភូមិ ។

## ជំពូកទី ២

## ការរៀបចំព្រះបរមងារ និង ព្រះរាជបុព្វសិទ្ធិ

**មាត្រា ២.–**

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** អតីត **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបានថ្វាយព្រះបរមងារជា **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ។

**សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ព្រះមហេសីនៃព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបានថ្វាយព្រះបរមងារជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ។**

**មាត្រា ៣.–**

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ត្រូវបានរក្សាព្រះរាជបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញនិង មិនអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គគង់នៅគ្រងរាជសម្បត្តិ ។

**មាត្រា ៤.-**

រាល់ការចំណាយរបស់អតីតព្រះមហាក្សត្រ និង ព្រះមហេសីនៃអតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាបន្ទុកនៃថវិកាជាតិ ។

**មាត្រា ៥.-**

អតីតព្រះមហាក្សត្រ និង ព្រះមហេសីនៃអតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាមានព្រះរាជសិទ្ធិជ្រើសរើស និង តែងតាំងគស្សរជននិងមន្ត្រីមួយចំនួនដើម្បីជាជំនួយការក្នុងការបំពេញព្រះរាជបេសកកម្ម ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

ពាណ.០៤១០.០០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

អត្ថលេខ ២៧៨ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]